**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃជំនួបរវាង ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ឯកឧត្តម ឃែលិដ ឃៀរី ឧបការីអគ្គលេខាធិការអង្គការសហប្រជាជាតិ

នៅព្រឹកថ្ងៃពុធ ទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានទទួល ឯកឧត្តម **ឃែលិដ ឃៀរី** (Khaled Khiari) ឧបការីអគ្គលេខាធិការអង្គការសហប្រជាជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

នៅក្នុងកិច្ចស្វាគមន៍ **ឯកឧត្តម ឃែលិដ ឃៀរី** សម្រាប់ដំណើរទស្សនកិច្ចជាលើកដំបូងមកកម្ពុជា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានលើកពីការរស់ឡើងវិញរបស់កម្ពុជាក្រោយឆ្នាំ១៩៧៩ និងការសម្រេចបាននូវសន្តិភាពយូរអង្វែង ការផ្សះផ្សារជាតិ និងការអភិវឌ្ឍផ្នែកសង្គមវប្បធម៌បន្ទាប់ពីការបញ្ចប់អាណត្តិរបស់អ៊ុនតាក់(UNTAC) នៅកម្ពុជាក្នុងឆ្នាំ១៩៩៣។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបង្ហាញនូវក្តីសង្ឃឹមថា បទពិសោធន៍របស់កម្ពុជាអាចត្រូវបានចែករំលែកក្នុងការនាំមកនូវសន្តិភាព និងស្ថិរភាពក្នុង និងក្រៅតំបន់។ **ឯកឧត្តម ឃែលិដ ឃៀរី** បានលើកសរសើរកម្ពុជាចំពោះវឌ្ឍនភាពជាលំដាប់ ការចូលរួមយ៉ាងធំធេងក្នុងការរក្សាសន្តិសុខអន្តរជាតិ និងការគាំទ្រពហុភាគីនិយម និងសណ្តាប់ធ្នាប់អន្តរជាតិដែលផ្អែកលើច្បាប់។ **ឯកឧត្តម** ក៏បានកោតសរសើរកម្ពុជាចំពោះយុទ្ធនាការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ១៩ ដ៏ជោគជ័យ ដែលនាំមកនូវការស្តារឡើងវិញដ៏ល្អនាពេលខាងមុខ និងគូសបញ្ជាក់អំពីការត្រៀមរួចជាស្រេចរបស់អង្គការសហប្រជាជាតិ ក្នុងការគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។

ចំពោះតួនាទីកម្ពុជាជាប្រធានអាស៊ានឆ្នាំ២០២២ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកពីអាទិភាពដែលកម្ពុជាបានកំណត់ដើម្បីកសាងសហគមន៍អាស៊ានបន្ថែមទៀត ក្រោមមូលបទ «អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា» ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានចែករំលែកទស្សនរបស់កម្ពុជាលើបញ្ហាតំបន់ ដោយលើកជាសំខាន់នូវការតាំងចិត្តរបស់កម្ពុជាក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពតំបន់ តាមរយៈការពង្រឹងកិច្ចខិតខំរួមគ្នាសម្រាប់ការស្តារឡើងវិញឆាប់រហ័សពីផលប៉ះពាល់ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ១៩ ដែលជាការប្រឈមចំពោះមជ្ឈភាព និងឯកភាពរបស់អាស៊ាន។

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

ចំពោះភាពដៃគូសន្ទនាគ្រប់ជ្រុងជ្រោយអាស៊ាន-អង្គការសហប្រជាជាតិ ដែលឈានដល់ខួបអនុស្សាវរីយ៍លើកទី១០ នៅឆ្នាំនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង ឯកឧត្តម ឃែលិដ យៀរី** បានពិភាក្សាអំពីការពន្លឿនកិច្ចសហប្រតិបត្តិការអាស៊ាន-អង្គការសហប្រជាជាតិក្នុងវិស័យមួយចំនួន ដែលមានកំណត់ក្នុងក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន ការបង្រួមគម្លាតអភិវឌ្ឍក្នុងអាស៊ានតាមរយៈការអនុវត្តផែនការការងារ IAI ទី៤ និងផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ សុខុមាលភាពពលករចំណាកស្រុក ស្ត្រីក្នុងរបៀបវារៈសន្តិភាព និងសន្តិសុខ និងការគាំទ្រមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC)។ ឯកឧត្តមទាំងពីរក៏បានចែករំលែកនូវទស្សនដូចគ្នាស្តីពីការលើកទឹកចិត្តអោយមានការសហការគ្នាជិតស្និទ្ធ រវាងប្រសិតពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ និងប្រេសិតពិសេសនៃប្រធានអាស៊ានស្តីពីបញ្ហាមីយ៉ាន់ម៉ា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង ឯកឧត្តម ឃែលិដ យៀរី** បានរំពឹងដល់វឌ្ឍនភាពបន្ថែមទៀតក្នុងការអនុវត្តផែនការសកម្មភាពអាស៊ាន-អង្គការសហប្រជាជាតិ ២០២១-២០២៥ រួមទាំងការជំរុញភាពបំពេញគ្នាទៅវិញទៅមករវាងចក្ខុវិស័យអាស៊ានឆ្នាំ២០២៥ និងរបៀបវារៈស្តីពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ឆ្នាំ2030 និងការរៀបចំកិច្ចប្រជុំអាស៊ាន-អង្គការសហប្រជាជាតិនៅគ្រប់កម្រិតដោយផ្ទាល់នៅឆ្នាំក្រោយ៕ ᴓ.

ថ្ងៃពុធ ០៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១